អត្ថបទព័ត៌មានថ្នាំចាក់បង្ការជំងឺ

ថ្នាំចាក់បង្ការជំងឺរលាកស្រោមខួរក្បាល

អ្វីដែលអ្នកត្រូវដឹង

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis
មានអត្ថបទព័ត៌មានថ្នាំចាក់បង្ការជាច្រើន សរសេរជាភាសាអេស្ប៉ាញ និងភាសាផ្សេងទៀត ។ សុបទស្សនាគេហទំព័រ www.immunize.org/vis ។

1 តើអ្វីជាជំងឺរលាកស្រោមខួរក្បាល?

ជំងឺរលាកស្រោមខួរ គឺជាជំងឺធ្ងន់ធ្ងរម៉្យាង ដែលបណ្តាលមកពីបាក់តេរី (bacterial illness) ។ វាគឺជាមូលហេតុចម្បង ចំពោះជំងឺរលាកស្រោមខួរបណ្តាលពីបាក់តេរី លើកុមារដែលមានអាយុពី 2 ទៅ 18ឆ្នាំ នៅសហរដ្ឋអាមេរិក ។ ជំងឺរលាកស្រោមខួរ គឺជាជំងឺឆ្លងរោគដែលវាគ្របដណ្តប់ក្នុងខួរក្បាល និងខួរឆ្អឹងខ្នង ។

ជំងឺរលាកស្រោមខួរក្បាល ក៏អាចបណ្តាលឲ្យមានមេរោគឆ្លងចូលក្នុងឈាមផងដែរ ។

នៅសហរដ្ឋអាមេរិក មានមនុស្សប្រហែលពី 1,000 – 1,200 នាក់កើតជំងឺរលាកស្រោមខួរក្បាលជារៀងរាល់ឆ្នាំ ។ បើទោះបីជាពួក គេបានទទួលការព្យាបាលដោយប្រើថ្នាំផ្សះក៏ដោយ ក៏អ្នកជំងឺទាំងនោះចំនួនពី 10-15% ត្រូវបានស្លាប់បាត់បង់ជីវិតដែរ ។ រីឯអ្នកនៅរស់វិញ មានចំនួនពី 11%-19% បានបាត់បង់ដៃ ឬជើង មានបញ្ហាជាមួយនឹងប្រព័ន្ធសរសៃប្រសាទ ភ្លាយជាមនុស្សថ្លង់ ឬក៏មានបញ្ហាពាក់ព័ន្ធនឹងជំងឺសរសៃប្រសាទ ឬក៏រីលក្នុងក្បាល ឬក៏ដាច់សរសៃឈាមក្នុងខួរក្បាល ។

ជំងឺនេះ អាចកើតនៅលើមនុស្សគ្រប់ប្រភេទ ។ តែជាធម្មតាវាកើតនៅលើទារកដែលមានអាយុក្រោមមួយឆ្នាំ និងជាមួយមនុស្សដែលមានអាយុចន្លោះពី 16-21 ឆ្នាំ ។ កុមារដែលស្ថិតក្រោមស្ថានភាពវជ្ជសាស្ត្រជាក់លាក់ណាមួយ ដូចជាជាលមិនប្រកតី តែងមានហានិភ័យខ្ពស់ក្នុងការកើតជំងឺរលាកស្រោមខួរក្បាល ។ និស្សិតឆ្នាំទីមួយ ដែលរស់នៅក្នុងសយនដ្ឋាន ក៏មានហានិភ័យខ្ពស់ក្នុងការកើតជំងឺនេះដែរ ។

ជំងឺរលាកស្រោមខួរក្បាល អាចព្យាបាលបានដោយប្រើថ្នាំ ដូចជាថ្នាំប៉េនីស៊ីលីន ជាដើម ។ ទោះជាមានថ្នាំព្យាបាលបានក៏ដោយ ក៏អ្នកជំងឺជាច្រើនបានស្លាប់ដោយសារជំងឺនេះដែរ ហើយមានអ្នកជំងឺជាច្រើនផ្សេងទៀតត្រូវទទួលរងផលប៉ះពាល់ ពីជំងឺនេះអស់មួយជីវិត ។ នេះហើយជាមូលហេតុសំខាន់ចំពោះមនុស្សដែលស្ថិតក្នុងហានិភ័យខ្ពស់ ត្រូវបង្ការជំងឺនេះ ដោយការចាក់ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល ។

2 ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល

ចំពោះថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល មានពីរប្រភេទ នៅសហរដ្ឋអាមេរិក ៖

- ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាលបែបដាក់បញ្ចូលគ្នា (Meningococcal conjugate vaccine-**MCV4**) គឺជាប្រភេទថ្នាំបង្ការ ដែលគេនិយមប្រើសម្រាប់មនុស្សដែលមានអាយុ 55 ឆ្នាំនិងក្មេងជាងនេះ ។
- ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាលប៉ូលីសាការីដ (**MPSV4**) មានប្រើប្រាស់តាំងពីទស្សវត្សរ៍ឆ្នាំ 1970 ។ វាគឺជាថ្នាំបង្ការជំងឺរលាក ស្រោមខួរតែម្យ៉ាងគត់ដែលបានទទួលអាជ្ញាប័ណ្ណឲ្យប្រើជាមួយមនុស្ស ដែលមានវ័យចំណាស់ជាង 55 ឆ្នាំ ។

ថ្នាំបង្ការទាំងពីរ អាចការពារជំងឺរលាកស្រោមខួរបានចំនួន 4ប្រភេទ ដោយរួមទាំង 2 ក្នុងចំនួន 3ប្រភេទដែលសាមញ្ញបំផុត នៅសហរដ្ឋអាមេរិក និងប្រភេទជំងឺដែលរាលដាលនៅទូទាំងទ្វីបអាហ្វ្រិក ។ វាមានជំងឺរលាកស្រោមខួរក្បាលប្រភេទផ្សេងៗទៀតដែរ ហើយថ្នាំបង្ការ មិនអាច ការពារជំងឺទាំងនេះបានទេ ។

3 នរណាដែលត្រូវចាក់ថ្នាំបង្ការ និងចាក់នៅពេលណា?

ការចាក់ថ្នាំបង្ការជាធម្មតា

មានការណែនាំឲ្យចាក់ថ្នាំបង្ការប្រភេទ MCV4 ចំនួនពីរដូស សម្រាប់មនុស្សពេញវ័យ ដែលមានអាយុពី 11 ទៅ18ឆ្នាំ ៖ ដូសដំបូងត្រូវចាក់ពេលដែលគេមានអាយុ 11 ឬ12ឆ្នាំ ហើយដូសទីពីរដែលជាដូសរំឭក ត្រូវចាក់ពេលដែលគេមានអាយុ 16ឆ្នាំ ។

ចំពោះមនុស្សពេញវ័យស្ថិតក្នុងអាយុនេះ ដែលឆ្លងមេរោគហ៊ីវ គួរចាក់ថ្នាំបង្ការចំនួនបីដូស ៖ 2 ដូសដំបូង ត្រូវចាក់ឃ្លាតពីគ្នាចំនួន 2ខែ ពេលដែលគេមានអាយុ 11 ឬ12ឆ្នាំ ហើយដូសចុងក្រោយ ត្រូវចាក់ពេលដែលគេមានអាយុ 16ឆ្នាំ ។

បើដូសដំបូង (ស៊េរីនៃការចាក់) ធ្វើឡើងពេលដែលគេអាយុពី 13 ទៅ15ឆ្នាំ ដូសរំឭក គួរចាក់ពេលដែលគេមានអាយុពី 16 ទៅ18ឆ្នាំ ។ ប្រសិនបើដូសដំបូង (ស៊េរីនៃការចាក់) ត្រូវចាក់ក្រោយពេលដែលគេមាន អាយុគ្រប់ 16ឆ្នាំ យើងមិនចាំបាច់ចាក់ដូសរំឭកទេ ។

មនុស្សផ្សេងទៀតដែលស្ថិតក្នុងហានិភ័យខ្ពស់

- និស្សិតឆ្នាំទីមួយនៃមហាវិទ្យាល័យ ដែលរស់នៅក្នុងសយនដ្ឋាន ។
- បុគ្គលិកមន្ទីរពិសោធន៍ ដែលប្រឈមជាមួយនឹងមេរោគរលាកស្រោមខួរក្បាលជាប្រចាំ ។
- អ្នកដែលចូលបំរើកងទ័ពសហរដ្ឋអាមេរិក ។
- អ្នកដែលធ្វើដំណើរទៅកាន់ ឬរស់នៅតាមតំបន់ផ្សេងៗក្នុងពិភពលោក ដែលមានជំងឺនេះកើតឡើង ដូចជាផ្នែកផ្សេងៗនៃទ្វីបអាហ្វ្រិក ។
- អ្នកដែលខូចជាល ឬអ្នកដែលត្រូវពេទ្យវះយកជាលចេញ ។
- អ្នកដែលមានប្រព័ន្ធភាងកាយទន់ខ្សោយជាប្រចាំ (មានបញ្ហាលើប្រព័ន្ធភាពស៊ាំរបស់រាងកាយ) ។
- អ្នកដែលអាចប្រឈមជាមួយនឹងជំងឺរលាកស្រោមខួរក្បាល ពេលដែលជំងឺនេះកំពុងរាតត្បាត ។

ទារកដែលមានអាយុពី 9 ទៅ23ខែ និងអ្នកដទៃដែលមានស្ថានភាពសុខភាពមិនល្អ ត្រូវការចាក់ចំនួន 2ដូស ដើម្បីធានាលើប្រសិទ្ធិភាព បង្ការ ។ ត្រូវសួរគ្រូពេទ្យរបស់អ្នកអំពីចំនួនដូស និងពេលវេលាដែលត្រូវចាក់ និងភាពត្រូវការនៃការចាក់ដូសរំឭក ។

MCV4 គឺជាថ្នាំបង្ការដែលគេនិយមចាក់ សម្រាប់មនុស្សស្ថិតក្នុងក្រុមទាំងនេះ គឺអ្នកដែលមានអាយុពី 9ខែ ទៅ55ឆ្នាំ ។ រីឯ MPSV4 អាចប្រើបានជាមួយមនុស្សចាស់ ដែលមានអាយុច្រើនជាង 55ឆ្នាំ ។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

4 អ្នកដែលមិនគួរចាក់ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល ឬគួររង់ចាំចាក់ពេលក្រោយ

- អ្នកដែលមានជំងឺប្រតិកម្មធាតុធ្ងន់ធ្ងរ (គំរាមហែងដល់ជីវិត) ចំពោះដូស MCV4 ឬ MPSV4 កាលពីពេលមុន មិនគួរចាក់ដូសណាមួយទៀតឡើយ ។
- អ្នកដែលមានជំងឺប្រតិកម្មធាតុ (គំរាមកំហែងដល់ជីវិត) ចំពោះថ្នាំបង្ការប្រភេទណាមួយ មិនគួរចាក់ថ្នាំបង្ការនេះឡើយ ។ *ចូរប្រាប់គ្រូពេទ្យរបស់អ្នកឲ្យបានដឹង ប្រសិនបើអ្នកមានជំងឺប្រតិកម្មធាតុធ្ងន់ធ្ងរ ។*
- អ្នកដែលមានជំងឺមធ្យម ឬធ្ងន់ ពេលដែលត្រូវចាក់ថ្នាំនេះ ហើយគួរ រង់ចាំរហូតដល់ជំងឺនេះជាសះស្បើយជាមុនសិន ។ សូរគ្រូពេទ្យរបស់អ្នកអំពីរឿងនេះ ។ អ្នកដែលមានជំងឺធ្ងន់មធ្យម ជាធម្មតា អាចចាក់ថ្នាំបង្ការ នេះបាន ។
- ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល អាចចាក់ឲ្យស្ត្រីដែលមានផ្ទៃពោះបាន ។ MCV4 គឺជាថ្នាំបង្ការថ្មីមួយ ហើយមិនទាន់បានយកទៅសិក្សា ជាមួយស្ត្រីមានផ្ទៃពោះ ដូចជាថ្នាំបង្ការ MPSV4 នៅឡើយទេ ។ វាអាចប្រើបានតែក្នុងករណីណាដែលមានការត្រូវការជាចាំបាច់ ។ អ្នកផលិត ថ្នាំបង្ការ MCV4 សូមមិនធានា ចំពោះស្ត្រីកំពុងពពោះ ដែលត្រូវចាក់ថ្នាំនេះ ។

លើកលែងតែកុមារដែលមានជំងឺឈាមក្រហមវាយប្រហារឈាមស ឬមានបញ្ហារឿងជាល យើងអាចចាក់ថ្នាំនេះឲ្យបាន ក្នុងពេលតែមួយនឹងថ្នាំបង្ការផ្សេងទៀតដែរ ។

5 តើអ្វីជាហានិភ័យចំពោះថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាល?

ថ្នាំបង្ការ ក៏ដូចជាឱសថទូទៅដែរ គឺអាចបង្កបញ្ហាធំៗ ដូចជា ប្រតិកម្ម ធ្ងន់ធ្ងរ ។ ហានិភ័យបណ្តាលពីថ្នាំបង្ការជំងឺរលាកស្រោមខួរ អាចបង្ករគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬផ្តាច់ជីវិតបាន តែភាគរយដែលកើតឡើងមានតិច តួចណាស់ ។

ខ្យល់ចាប់ក្នុងរយៈពេលខ្លី និងរោគសញ្ញាផ្សេងទៀតដែលពាក់ព័ន្ធ (ដូចជាឈឺងចោង ឬវិលក្នុងក្បាល) អាចកើតឡើង បន្ទាប់ពីចាក់រូច ។ វាកើតមានជាញឹកញាប់ ចំពោះមនុស្សធំ ហើយវាអាច ធ្វើឲ្យអ្នកដួល ហើយរបួសបាន ។

ការអង្គុយ ឬដេកចំនួន 15នាទី ក្រោយពីការចាក់រូច ជាពិសេសបើអ្នកមានអារម្មណ៍ថាខ្យល់ចាប់ អាចជួយការពារមិនឲ្យ មានរបួសស្នាមបាន ។

បញ្ហាមធ្យម

មានអ្នកដែលចាក់ថ្នាំបង្ការជំងឺរលាកស្រោមខួរក្បាលនេះ ចំនួនពាក់កណ្តាល បានទទួលផលប៉ះពាល់ ដូចជាឡើងក្រហម ឬឈឺត្រង់បរិវេណចាក់ ។

បើមានបញ្ហាទាំងនេះកើតឡើង វានឹងបាត់ទៅវិញ ពី1 ទៅ2ថ្ងៃ ។ វាកើតឡើងជាធម្មតា ក្រោយពេលចាក់ថ្នាំបង្ការ MCV4 ជាងថ្នាំបង្ការ MPSV4 ។

មានភាគរយតិចតួច ចំពោះអ្នកដែលចាក់ថ្នាំបង្ការនេះរួចហើយ ក្លាយជាគ្រុននោះ ។

បញ្ហាធ្ងន់ធ្ងរ

ប្រតិកម្មធាតុធ្ងន់ធ្ងរ ក្នុងរវាងពីរបីនាទី ទៅពីរបីម៉ោង ក្រោយពីការចាក់ គឺជាករណីដែលកម្រកើតមានណាស់ ។

DCH–0930CA
AUTH: P.H.S., Act 42, Sect. 2126.

6 តើត្រូវធ្វើដូចម្តេច ប្រសិនបើមានប្រតិកម្មមធ្យម ឬធ្ងន់ធ្ងរកើតឡើង?

ខ្ញុំត្រូវរកមើលអ្វីខ្លះ?

គួររកមើលស្ថានភាពមិនប្រកតីណាមួយ ដូចជាប្រតិកម្មធាតុធ្ងន់ធ្ងរ ឬគ្រុនក្តៅខ្លាំង ។ បើកើតមានប្រតិកម្មធាតុធ្ងន់ធ្ងរ ក្រោយពីការចាក់រូច វានឹងកើតឡើងចំនួនពីរបីនាទី ទៅមួយម៉ោង ។ សញ្ញាថានឹងកើតមានប្រតិកម្មធាតុធ្ងន់ធ្ងរ អាចមានដូចជាពិបាកដកដង្ហើម ខ្សោយក្នុងខ្លួន ដកដង្ហើមឮយឺសៗ ឬឃុសៗ បេះដូងដើរលឿន ឡើងបន្ទាលត្រអាក វិលមុខ ស្លេកស្លាំង ឬ ហើមបំពង់ក ។

តើខ្ញុំត្រូវធ្វើដូចម្តេច?

- ទូរស័ព្ទជូបគ្រូពេទ្យ ឬយកអ្នកជំងឺទៅជូបគ្រូពេទ្យជាបន្ទាន់ ។
- ប្រាប់គ្រូពេទ្យរបស់អ្នកពីអ្វីដែលបានកើតឡើង កាលបរិច្ឆេទ និងពេលវេលាដែលបានកើតឡើង និងពេលវេលាដែលបានចាក់ថ្នាំបង្ការនេះ ។
- សូមឲ្យអ្នកផ្តល់សេវារបស់អ្នក រាយការណ៍អំពីប្រតិកម្មនេះ ដោយការបំពេញបែបបទ Vaccine Adverse Event Reporting System (VAERS-ប្រព័ន្ធរបាយការណ៍ប្រតិកម្មបញ្ហាសរបស់ថ្នាំបង្ការ) ។ ឬមួយអ្នកអាចធ្វើរបាយការណ៍នេះតាមរយៈគេហទំព័រ VAERS ដែលមានអាសយដ្ឋាន **www.vaers.hhs.gov** ឬដោយការហៅទូរស័ព្ទ ទៅកាន់លេខ **1-800-822-7967** ។

VAERS មិនផ្តល់ដំបូន្មានផ្នែកវេជ្ជសាស្ត្រទេ ។

7 កម្មវិធីជាតិសំណងទូទាត់របួសស្នាមពីការចាក់ថ្នាំបង្ការ

National Vaccine Injury Compensation Program (VICP-កម្មវិធីជាតិ សំណងទូទាត់របួសស្នាមពីការចាក់ថ្នាំបង្ការ) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1986 ។

អ្នកណាដែលជឿថា ខ្លួនអាចមានរបួសស្នាម ពីថ្នាំបង្ការ អាចសិក្សា កម្មវិធីនេះ និងរបៀបដាក់ពាក្យទាមទារសំណង ដោយការហៅទូរស័ព្ទ មកកាន់លេខ **1-800-338-2382** ឬទស្សនាគេហទំព័រ VICP តាមរយៈអាសយដ្ឋាន **www.hrsa.gov/vaccinecompensation** ។

8 តើខ្ញុំអាចដឹងព័ត៌មានបន្ថែមដោយរបៀបណា?

- គ្រូពេទ្យរបស់អ្នកអាចផ្តល់ឲ្យអ្នកនូវឯកសារអំពីថ្នាំបង្ការ ឬមួយគាត់អាចណែនាំអ្នក ពីប្រភពនៃព័ត៌មានដល់អ្នកបាន ។
- ចូរហៅទូរស័ព្ទទៅជូបគ្រូពេទ្យរបស់អ្នក ឬហៅទូរស័ព្ទទៅកាន់ក្រសួងសុខាភិបាលរបស់រដ្ឋ ។ 1–888–767–4687
- ចូរទំនាក់ទំនងជាមួយនឹង Centers for Disease Control and Prevention (CDC-មជ្ឈមណ្ឌលគ្រប់គ្រង និងការពារជំងឺឆ្លង) ៖
  - ទូរស័ព្ទលេខ 1-800-232-4636 (**1-800-CDC-INFO**) ឬ
  - ទស្សនាគេហទំព័រ CDC តាមអាសយដ្ឋាន **www.cdc.gov/vaccines**

Vaccine Information Statement (Interim)

Meningococcal Vaccines

Cambodian

10/14/2011

42 U.S.C. § 300aa-26

Translated by Carmazzi Global Solutions, CA

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណាត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ព័ត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។